ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យអង្គរ

# យន្តការជំរុញ និងគ្រប់គ្រងហានិភ័យក្នុងបរិបទក្រោយកូវីដ-១៩

## ផែនការប្រតិបត្តិសម្រាប់ឆ្នាំសិក្សា ២០២១-២០២២

ខែ ធ្នូ ឆ្នាំ ២០២១

# យន្តការជំរុញ និងគ្រប់គ្រងហានិភ័យក្នុងបរិបទក្រោយកូវីដ-១៩

## ផែនការប្រតិបត្តិសម្រាប់ឆ្នាំសិក្សា ២០២១-២០២២

**ខែ ធ្នូ ឆ្នាំ ២០២១**

**ក. ក្រុមការងារដឹកនាំ និងរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ**

| | | | |
|---|---|---|---|
| ១. បណ្ឌិត ញិល រដ្ឋា | ប្រធាន | ២. លោក ជា វណ្ណៈ | អនុប្រធាន |
| ៣. វេជ្ជ ញូង ភក្តី | សមាជិក | ៤. លោក អយ លាងសេង | សមាជិក |
| ៥. លោក ទិតសុទ្ធី ឱយ៉ាណូរីន | សមាជិក | ៦. អ្នកស្រី សរ សីលៀង | សមាជិក |
| ៧. អ្នកស្រី យឹម ផល្លីកា | សមាជិក | ៨. លោក ថេន បញ្ញាណា | សមាជិក |
| ៩. កញ្ញា សូ ស្រីលីស | សមាជិក | ១០. កញ្ញា លាម ស្រីយ៉ា | លេខា |

**ខ. ក្រុមការងារត្រួតពិនិត្យខ្លឹមសារ និងអនុម័តដាក់ឲ្យប្រើប្រាស់របាយការណ៍**

| | | | |
|---|---|---|---|
| ១. ឯកឧត្តម បណ្ឌិត សៀង ណាំ | ប្រធាន | ២. លោក សុខ គុញ | អនុប្រធាន |
| ៣. បណ្ឌិត ញិល រដ្ឋា | សមាជិកអចិន្ត្រៃយ៍ | ៤. លោក ហៀក ណារិទ្ធ | សមាជិក |
| ៥. លោក ម៉េង ហ៊ាង | សមាជិក | | |

**គ. ក្រុមការងារផ្ដល់យោបល់**

១. ឯកឧត្តម បណ្ឌិតសភាចារ្យ ហ៊ីង ថូរ៉ាក់ស៊ី
២. លោកស្រី ស៊ិន សុខា
៣. នាយកដ្ឋានឧត្តមសិក្សានៃ អយក.
៤. នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃ សខល

**ឃ. ក្រុមការងារវាយអត្ថបទ**

១. កញ្ញា លាម ស្រីយ៉ា

**ង. ក្រុមការងារបច្ចេកទេសឌីហ្សាញ និងរចនា**

១. លោក ចាន់ សែនសំណាង ២. លោក ម៉ៅ បូរី ៣. លោក មឿក អែប
៤. លោក រ៉េន វីរៈ

**ច. ក្រុមការងារបច្ចេកទេស និងត្រួតពិនិត្យអក្ខរាវិរុទ្ធ**

១. លោក ជា វណ្ណៈ ២. អ្នកស្រី សរ សីលៀង ៣. លោក យឿន ស្រស់
៤. កញ្ញា វ៉ាត ស្រីលាក់ ៥. លោក ឈួយ វណ្ណធា

**បោះពុម្ពលើកទី១**

រក្សាសិទ្ធិគ្រប់យ៉ាង © ២០២១ ដោយ**មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីឧត្តមភាព និងនវានុវត្តន៍របស់សាកលវិទ្យាល័យអង្គរ**។ គ្មានផ្នែកណាមួយនៃសៀវភៅនេះ ត្រូវបានផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីម្ចាស់កម្មសិទ្ធិឡើយ ទោះតាមរូបភាព ឬមធ្យោបាយណាមួយក៏ដោយ។

**បោះពុម្ព ខែធ្នូ ឆ្នាំ២០២១**

# អារម្ភកថា

ផែនការប្រតិបត្តិប្រចាំឆ្នាំសិក្សា២០២១-២០២២ ត្រូវបានចងក្រង និងកែលម្អដោយថ្នាក់ដឹកនាំរបស់សាកលវិទ្យាល័យអង្គរ (ស.អ.) ដោយយោងតាមផែនការយុទ្ធសាស្ត្រ ២០១៨-២០២៣ «វិថីអេយូទំនោរជោគជ័យ»។ គោលដៅសំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្ររួមមាន ការពង្រឹងការគ្រប់គ្រងប្រកបដោយភាពជាអ្នកដឹកនាំ ការបង្កើនគុណភាពអប់រំប្រកបដោយនិរន្តរភាព ការស្រាវជ្រាវនិងការអភិវឌ្ឍ ការទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ និងការទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិនិងអន្តរជាតិ។

ផែនការប្រតិបត្តិនេះ រចនាឡើងក្នុងបរិបទក្រោយកូវីដ-១៩ ក្នុងខណៈដែល ស.អ. ចាប់ផ្តើមពង្រឹងនិងពង្រីកការផ្តល់សេវាកម្មអប់រំ ជាពិសេសកំពុងបង្កើនកិត្យានុភាពក្នុងក្របខ័ណ្ឌការប្រកួតប្រជែងប្រកបដោយភាពទំនួលខុសត្រូវ និងស្ថានភាពប្រឈមនៃការរីករាលដាលជំងឺឆ្លងអូមីក្រុង។ ដូចនេះ ផែនការប្រតិបត្តិត្រូវបានផ្តល់ឈ្មោះថា «យន្តការជំរុញ និងគ្រប់គ្រងហានិភ័យក្នុងបរិបទក្រោយកូវីដ-១៩»។

«យន្តការជំរុញ និងគ្រប់គ្រងហានិភ័យក្នុងបរិបទក្រោយកូវីដ-១៩» ត្រូវបានចែកចេញជា ៨ ជំពូក ដែលជំពូក ១ រៀបរាប់អំពីអាសយដ្ឋាន លិខិតូបករណ៍ផ្លូវការ អាជ្ញាប័ណ្ណអនុញ្ញាត និងមុខជំនាញដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជននិងកីឡា និង ក្រសួងសុខាភិបាល។ នៅត្រង់ជំពូក ២ មានការពន្យល់អំពីចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងអត្តន័យឡូហ្គោ។ ក្រៅពីនេះ ជំពូក ៣ បង្ហាញអំពីគោលដៅយុទ្ធ-សាស្ត្រ និងទិសដៅយុទ្ធសាស្ត្រ សម្រាប់ការបន្តរៀបចំ និងអភិវឌ្ឍ ស.អ. ស្របតាមបរិបទក្រោយកូវីដ-១៩។ ជំពូក ៤ ត្រូវបានរំលេចអំពីលទ្ធផលរំពឹងទុក និងសកម្មភាពការងារលម្អិតសម្រាប់បង្កើនភាពងាយស្រួលក្នុងការអនុវត្តរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់។ សម្រាប់ ជំពូក ៥ ត្រូវបានសង្កត់ធ្ងន់លើសកម្មភាពលម្អិតស្របតាមសកម្មភាពចម្បង កាលបរិច្ឆេទ និងអ្នកទទួលខុសត្រូវច្បាស់លាស់ ព្រមទាំងមានបង្ហាញនូវប្រភពចំណាយដែលទាញចេញពីអនុគណនី នៃផែនការហិរញ្ញវត្ថុ។ ចំណែកឯ ជំពូក ៦ បានបង្ហាញអំពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងយ៉ាងច្បាស់លាស់ ដើម្បីធ្វើឱ្យការងារមានប្រសិទ្ធភាពខ្ពស់។ ក្រៅពីនេះ ជំពូក ៧ បានសង្កត់ធ្ងន់លើការពិនិត្យ តាមដាន និងវាយតម្លៃលើផែនការប្រតិបត្តិប្រចាំឆ្នាំនេះ។ ជាចុងក្រោយ ជំពូក ៨ បានធ្វើការសន្និដ្ឋានលើផែនការដែលមានឈ្មោះថា «យន្តការជំរុញ និងគ្រប់គ្រងហានិភ័យក្នុងបរិបទក្រោយកូវីដ-១៩»។

ផែនការនេះ ជាមូលដ្ឋានដ៏រឹងមាំ និងជាផែនទីដ៏ច្បាស់លាស់ដើម្បីចង្អុលបង្ហាញនិងតម្រង់ទិសដល់ក្រុមការងារ ជាពិសេសថ្នាក់ដឹកនាំក្នុងការគ្រប់គ្រង តាមដាន វាយតម្លៃប្រកបដោយស្មារតីទទួលខុសត្រូវ និងនិរន្តរភាព របស់អង្គភាព។

ក្នុងនាមជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យអង្គរ និងជាប្រធានក្រុមការងារដឹកនាំការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសិក្សា២០២១-២០២២ សូមសម្តែងនូវអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះសមាជិកផ្តល់យោបល់ ក្រុមការងារសម្របសម្រួល ក្រុមការងារបច្ចេកទេសឌីហ្សាញនិងរចនា និងក្រុមការងារបច្ចេកទេសនិងត្រួតពិនិត្យ អក្ខរាវិរុទ្ធ ព្រមទាំងក្រុមប្រឹក្សាភិបាល សាកលវិទ្យាធិការរង សមាជិក/សមាជិការក្រុមប្រឹក្សាអប់រំនិងបណ្តុះបណ្តាល ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រឹទ្ធបុរស/ព្រឹទ្ធបុរសរង ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ ប្រធាន/អនុប្រធានការិយាល័យ អង្គភាពចំណុះ គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិតដែលបាន

ចូលរួមចំណែកក្នុងការកសាងនូវផែនការប្រតិបត្តិតាមរយៈយោបល់ ទស្សនាទាន និងគំនិតនានា ប្រកបដោយស្មារតីយោគយល់ និងចក្ខុវិស័យវែងឆ្ងាយ។

ជាចុងក្រោយខ្ញុំសូមជូនពរដល់ក្រុមការងារទាំងអស់ដែលបានរៀបរាប់ខាងលើឱ្យជួបនូវ ពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

ថ្ងៃពុធ ០៥រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥<br>
ក្រុងសៀមរាប ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១<br>
**សាកលវិទ្យាធិការ**

# មាតិកា


អារម្ភកថា ....... i

មាតិកា ....... iii

បញ្ជីតារាង ....... viii

បញ្ជីអក្សរកាត់ ....... ix

**លទ្ធផលសំខាន់ៗ និងបញ្ហាប្រឈមឆ្នាំ២០២០-២០២១ ....... x**

សេចក្តីសម្រេចដាក់ឱ្យប្រើប្រាស់ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២១-២០២២ ....... xi

**ជំពូក ១ ....... ១**

**សេចក្តីផ្តើម ....... ១**

**ជំពូក ២ ....... ៧**

**ចក្ខុវិស័យ បេសកកម្ម គម្លៃស្នូល និងអត្តសញ្ញាណឡូហ្គោ ....... ៧**

២.១. ចក្ខុវិស័យ ....... ៧

២.២. បេសកកម្ម ....... ៧

២.៣. គម្លៃស្នូល ....... ៧

**ជំពូក ៣ ....... ៩**

**គោលដៅយុទ្ធសាស្ត្រ និងទិសដៅយុទ្ធសាស្ត្រ ....... ៩**

៣.១. គោលដៅយុទ្ធសាស្ត្រ ....... ៩

៣.២. ទិសដៅយុទ្ធសាស្ត្រ ....... ៩

៣.២.១- ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចច្បាស់លាស់ ....... ៩

៣.២.២- ការលើកកម្ពស់សមត្ថភាពបុគ្គលិក និងការលើកទឹកចិត្ត ....... ៩

៣.២.៣- ការរៀបចំយន្តការដឹកនាំគ្រប់គ្រង និងប្រតិបត្តិការច្បាស់លាស់ ....... ៩

៣.២.៤- ការកំណត់ប្រព័ន្ធតាមដាន និងវាយតម្លៃជាក់លាក់ ....... ៩

៣.២.៥- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ....... ១០

៣.២.៦- ការអភិវឌ្ឍកម្មវិធីសិក្សាជាតិ និងអន្តរជាតិ ....... ១០

៣.២.៧- ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន/សាស្ត្រាចារ្យ ....... ១០

៣.២.៨- ការអភិវឌ្ឍសម្ភាររូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ ....... ១០

៣.២.៩- ការលើកកម្ពស់គុណភាពសិក្សា និងការស្រាវជ្រាវ ....... ១១

៣.២.១០- ការបង្កើនគុណភាពផ្តល់សេវាកម្មនិស្សិត ....... ១១

៣.២.១១- ការរៀបចំការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍសាកលវិទ្យាល័យ ....... ១១

៣.២.១២- ការបង្កើតវប្បធម៌ស្រាវជ្រាវ និងអំណាននិស្សិត ....... ១១

៣.២.១៣- ការបង្កើតវប្បធម៌ស្រាវជ្រាវរបស់បុគ្គលិក និងគ្រូបង្រៀន/សាស្ត្រាចារ្យ ....... ១១

៣.២.១៤- ការធ្វើទំនើបកម្ម និងនវានុវត្តន៍ឯកសារសម្រាប់ស្រាវជ្រាវ ....... ១១

៣.២.១៥- ការបោះពុម្ព និងផ្សព្វផ្សាយ ....... ១២

៣.២.១៦- ការពង្រឹង និងពង្រីកភាពជាដៃគូសហប្រតិបត្តិការ ........ ១២
៣.២.១៧- ការផ្លាស់ប្តូរវប្បធម៌ ........ ១២
៣.២.១៨- ការផ្តល់អាហារូបករណ៍ ........ ១៣
៣.២.១៩- ការស្រាវជ្រាវរួមគ្នា ........ ១៣
៣.២.២០- ការរៀបចំប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ........ ១៣
៣.២.២១- ដំណើរការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង ........ ១៣
៣.២.២២- ការវាយតម្លៃគុណភាពអប់រំថ្នាក់ជាតិ/អន្តរជាតិ ........ ១៣
**ជំពូក ៤ ........ ១៤**
**លទ្ធផលរំពឹងទុក និងសកម្មភាពចម្បង ........ ១៤**
**៤.១. ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចច្បាស់លាស់ ........ ១៤**
៤.១.១- ពិនិត្យការអនុវត្តការងារស្របតាមប្រព័ន្ធគ្រប់គ្រងរួម ........ ១៤
**៤.២. ការលើកកម្ពស់សមត្ថភាពបុគ្គលិក និងការលើកទឹកចិត្ត ........ ១៤**
៤.២.១- បង្កើតសម្ថភាពបុគ្គលិករដ្ឋបាល ........ ១៤
៤.២.២- លើកទឹកចិត្តបុគ្គលិកគ្រប់កម្រិត ........ ១៤
**៤.៣. ការរៀបចំយន្តការដឹកនាំគ្រប់គ្រង និងប្រតិបត្តិការច្បាស់លាស់ ........ ១៥**
៤.៣.១- កំណត់យន្តការដឹកនាំ និងគ្រប់គ្រង ........ ១៥
៤.៣.២- កំណត់ប្រព័ន្ធប្រតិបត្តិការ ........ ១៥
**៤.៤. ការកំណត់ប្រព័ន្ធតាមដានការងារ ........ ១៥**
៤.៤.១- កំណត់ប្រព័ន្ធតាមដានការងារ ........ ១៥
៤.៤.២- វាយតម្លៃការងារ ........ ១៥
**៤.៥. ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ........ ១៦**
៤.៥.១- កំណត់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ........ ១៦
៤.៥.២- ធ្វើសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ ២០២១-២០២២ ........ ១៦
**៤.៦. ការអភិវឌ្ឍកម្មវិធីសិក្សាជាតិ និងអន្តរជាតិ ........ ១៦**
៤.៦.១- បកប្រែមុខវិជ្ជាក្នុងកម្មវិធីសិក្សាពីភាសាអង់គ្លេសមកភាសាខ្មែរគ្រប់កម្រិត ........ ១៦
៤.៦.២- បញ្ចូលកូដមុខវិជ្ជាក្នុងកម្មវិធីសិក្សាគ្រប់កម្រិត ........ ១៦
៤.៦.៣- ចងក្រងសៀវភៅកម្មវិធីបណ្តុះបណ្តាលតាមមុខជំនាញគ្រប់កម្រិត ........ ១៧
៤.៦.៤- ស្រាវជ្រាវអំពីភាពពេញចិត្តលើកម្មវិធីសិក្សាដែលកំពុងបណ្តុះបណ្តាល ........ ១៧
៤.៦.៥- បន្តអភិវឌ្ឍសៀវភៅគោល តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល ........ ១៧
៤.៦.៦- បន្តស្រាវជ្រាវសៀវភៅយោងបន្ថែមតាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល ........ ១៧
៤.៦.៧- ប្រជុំផ្សព្វផ្សាយកម្មវិធីសិក្សា ........ ១៨
**៤.៧. ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន/សាស្ត្រាចារ្យ ........ ១៨**
៤.៧.១- បន្តធ្វើការស្ទង់មតិគ្រូបង្រៀន/សាស្ត្រាចារ្យ អំពីការពេញចិត្តចំពោះ ស.អ. ........ ១៨

៤.៧.២- បន្តលើកទឹកចិត្តគ្រូបង្រៀន/សាស្ត្រាចារ្យ ..................................................... ១៨
៤.៧.៣- រៀបចំសិក្ខាសាលាស្តីពីវិធីសាស្ត្របង្រៀន ..................................................... ១៨
**៤.៨. ការអភិវឌ្ឍសម្ភារូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ** ..................................................... ១៩
៤.៨.១- ពិនិត្យ វាយតម្លៃសម្ភារូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ ..................................................... ១៩
៤.៨.២- បង្កើននិងអភិវឌ្ឍសំណង់អគារថ្មី..................................................... ១៩
៤.៨.៣- អភិវឌ្ឍសម្ភារូបវន្តសម្រាប់មហាវិទ្យាល័យសុខភាពសាធារណៈ..................................................... ១៩
៤.៨.៤- អភិវឌ្ឍសម្ភារូបវន្តសម្រាប់មហាវិទ្យាល័យវិស្វកម្ម និងស្ថាបត្យកម្ម..................................................... ១៩
៤.៨.៥- អភិវឌ្ឍសម្ភារូបវន្តសម្រាប់មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ..................................................... ២០
៤.៨.៦- អភិវឌ្ឍសម្ភារូបវន្តសម្រាប់មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ .. ២០
៤.៨.៧- អភិវឌ្ឍសម្ភារូបវន្តសម្រាប់មហាវិទ្យាល័យសង្គមសាស្ត្រ និងនីតិសាស្ត្រ..................................................... ២០
**៤.៩. ការលើកកម្ពស់គុណភាពសិក្សា និងការស្រាវជ្រាវ** ..................................................... ២០
៤.៩.១- ផ្សព្វផ្សាយ និងតម្រង់ទិសអំពីបទបញ្ជាផ្ទៃក្នុងនិស្សិតគ្រប់កម្រិត ..................................................... ២០
៤.៩.២- ពង្រឹងគុណភាពសិក្សា និងចំនួនបញ្ចប់របស់និស្សិត..................................................... ២១
៤.៩.៣- បង្កើនកម្មវិធីអភិវឌ្ឍសមត្ថភាព និងការសិក្សានិងស្រាវជ្រាវបន្ថែមលើ
កម្មវិធីសិក្សាដែលមាននៅក្នុងកម្រិតសិក្សារបស់ខ្លួន ..................................................... ២១
**៤.១០. ការបង្កើនគុណភាពផ្តល់សេវាកម្មនិស្សិត** ..................................................... ២១
៤.១០.១- បង្កើនតម្លាភាពក្នុងការផ្តល់ព័ត៌មានអំពីសកម្មភាពបណ្តុះបណ្តាល
និងសេវាគាំទ្រ ..................................................... ២១
៤.១០.២- ជួយសម្របសម្រួលដល់និស្សិតក្នុងសកម្មភាពស្ម័គ្រចិត្ត និងកិច្ចការសង្គម........ ២២
**៤.១១. ការរៀបចំការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍសាកលវិទ្យាល័យ**..................................................... ២២
៤.១១.១- រៀបចំយន្តការស្រាវជ្រាវគោលការណ៍ និងនីតិវិធីស្រាវជ្រាវរបស់ ស.អ. ............ ២២
៤.១១.២- រៀបចំយុទ្ធនាការបង្កើនគម្រោងស្រាវជ្រាវ..................................................... ២២
**៤.១២. ការបង្កើតវប្បធម៌ស្រាវជ្រាវ និងអំណាននិស្សិត** ..................................................... ២៣
៤.១២.១- បង្កើតកម្មវិធីប្រកួតប្រជែងស្នាដៃរបស់និស្សិត..................................................... ២៣
**៤.១៣. ការបង្កើតវប្បធម៌ស្រាវជ្រាវរបស់បុគ្គលិក និងគ្រូបង្រៀន/សាស្ត្រាចារ្យ** ..................................................... ២៣
៤.១៣.១- រៀបចំមូលនិធិស្រាវជ្រាវ ..................................................... ២៣
៤.១៣.២- ជំរុញបុគ្គលិក និងគ្រូបង្រៀនចូលរួមស្រាវជ្រាវ ..................................................... ២៣
**៤.១៤. ការធ្វើទំនើបកម្ម និងនវានុវត្តឯកសារសម្រាប់ស្រាវជ្រាវ**..................................................... ២៣
៤.១៤.១- ជំរុញ និងបង្កើតវប្បធម៌ប្រើប្រាស់ប្រព័ន្ធឌីជីថល ..................................................... ២៤
**៤.១៥. ការបោះពុម្ព និងផ្សព្វផ្សាយ**..................................................... ២៤
៤.១៥.១- ចងក្រងឯកសារតូបករណ៍គ្រប់ប្រភេទ ..................................................... ២៤
៤.១៥.២- បោះពុម្ពឯកសារតូបករណ៍ និងឯកសារគាំទ្រគ្រប់ប្រភេទ
ព្រមទាំងវត្ថុអនុស្សាវរីយ៍..................................................... ២៤

**៤.១៦. ការពង្រឹង និងពង្រីកភាពជាដៃគូសហប្រតិបត្តិការ** ........ ២៥
៤.១៦.១- បង្កើនដៃគូកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ........ ២៥
៤.១៦.២- ពង្រីកបណ្ដាញទំនាក់ទំនងតាមប្រព័ន្ធបច្ចេកវិទ្យា ........ ២៥
**៤.១៧. ការផ្លាស់ប្ដូរវប្បធម៌** ........ ២៥
៤.១៧.១- បង្កើតឱកាសទស្សនកិច្ចសិក្សា ចូលរួមវេទិកា សិក្ខាសាលា វគ្គបណ្ដុះបណ្ដាល និងព្រឹត្តិការណ៍នានា នៅក្នុងប្រទេស និងបរទេស........ ២៦
៤.១៧.២- បង្កើតវេទិកា សិក្ខាសាលា វគ្គបណ្ដុះបណ្ដាល និងព្រឹត្តិការណ៍នានា នៅ ស.អ. ........ ២៦
**៤.១៨. ការផ្ដល់អាហាររូបករណ៍**........ ២៦
៤.១៨.១- កំណត់ចំនួន និងប្រភេទអាហាររូបករណ៍........ ២៦
៤.១៨.២- បង្កើតមូលនិធិសម្រាប់គាំទ្រដល់ការផ្ដល់អាហាររូបករណ៍ ........ ២៧
**៤.១៩. ការស្រាវជ្រាវរួមគ្នា**........ ២៧
៤.១៩.១- បង្កើនគម្រោងស្រាវជ្រាវរួមគ្នា ........ ២៧
៤.១៩.២- បង្កើតវប្បធម៌ស្រាវជ្រាវរួមគ្នា ........ ២៧
**៤.២០. ការរៀបចំប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង**........ ២៧
៤.២០.១- បង្កើតស្ដង់ដាធានាគុណភាពអប់រំផ្ទៃក្នុងរបស់ ស.អ. ........ ២៨
៤.២០.២- ជំរុញដំណើរការប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ........ ២៨
**៤.២១. ដំណើរការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង** ........ ២៨
៤.២១.១- រៀបចំនិទ្ទេសបទស្វ័យវាយតម្លៃ........ ២៨
៤.២១.២- បង្កើតវប្បធម៌ស្វ័យវាយតម្លៃ ........ ២៨
**៤.២២. ការវាយតម្លៃគុណភាពអប់រំថ្នាក់ជាតិ/អន្តរជាតិ**........ ២៩
៤.២២.១- ចូលរួមអនុវត្តស្ដង់ដារបស់ គ.ទ.ក អគ្គនាយកដ្ឋានឧត្តមសិក្សា និងនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីត្រៀមខ្លួនវាយតម្លៃ ........ ២៩
៤.២២.២- សិក្សាអំពីអត្ថប្រយោជន៍របស់ស្ដង់ដា ISO........ ២៩
**ជំពូក ៥** ........ **៣១**
**ផែនការសកម្មភាព** ........ **៣១**
**ជំពូក ៦** ........ **៥៤**
**ការគ្រប់គ្រងហិរញ្ញវត្ថុ**........ **៥៤**
**ជំពូក ៧** ........ **៥៨**
**ការពិនិត្យ តាមដាន និងវាយតម្លៃ** ........ **៥៨**
៧.១. ការកំណត់ក្រុមការងារ ........ ៥៨
៧.២. រៀបចំកាលបរិច្ឆេទលម្អិតសម្រាប់ការបង្កើតផែនការប្រតិបត្តិ........ ៥៨
៧.៣. ហិរញ្ញវត្ថុសម្រាប់រៀបចំផែនការប្រតិបត្តិ........ ៥៩

៧.៤. ការកំណត់នីតិវិធីតាមដាន និងការអនុវត្តផែនការ ....... ៥៩
**ជំពូក ៨ ....... ៦០**
**កត្តាប្រឈម និងសេចក្ដីសន្និដ្ឋាន ....... ៦០**

# បញ្ជីតារាង

តារាងទី០១ ៖ និន្នាការនៃចំនួនបុគ្គលិក គ្រូបង្រៀន/សាស្រ្តាចារ្យ និស្សិត និងដៃគូអភិវឌ្ឍន៍.................... ix
តារាងទី០២ ៖ មុខជំនាញ និងកម្រិតបណ្តុះបណ្តាលតាមមហាវិទ្យាល័យ .......................................... ២
តារាងទី០៣ ៖ សកម្មភាពការងារ និងភាពទំនួលខុសត្រូវ ............................................................ ៣០
តារាងទី០៤ ៖ ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២១-២០២២ ..................................................៥៦
តារាងទី០៥ ៖ សកម្មភាពតាមដាន ត្រួតពិនិត្យ និងទំនួលខុសត្រូវ ..................................................៦០
តារាងទី០៦ ៖ រយៈពេលសម្រាប់រៀបចំ និងអនុម័តផែនការប្រតិបត្តិ................................................៦០
តារាងទី០៧ ៖ ហិរញ្ញវត្ថុសម្រាប់ការរៀបចំផែនការ.....................................................................៦១
តារាងទី០៨ ៖ នីតិវិធីតាមដាន និងការអនុវត្តផែនការ ..................................................................៦១

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| គ.ទ.ក | ៖ | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា |
| គ.វ.ល | ៖ | គណៈកម្មការវាយតម្លៃ និងលើកទឹកចិត្តបុគ្គលិក |
| គ.ហ | ៖ | ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ |
| គ.ហ.ស | ៖ | គណៈកម្មការហិរញ្ញវត្ថុ និងសវនកម្ម |
| គ.អ.ក.ស | ៖ | គណៈកម្មការអភិវឌ្ឍន៍កម្មវិធីសិក្សា |
| គ.ព.ប្រ | ៖ | គណៈកម្មការពិធីការ និងរៀបចំប្រជុំ |
| គ.ហ.ផ | ៖ | គណៈកម្មការគ្រប់គ្រងហ្វេសប៊ុកផេក |
| គ.គ.ស.ម | ៖ | គណៈកម្មការគ្រប់គ្រងការស្ទង់មតិ |
| គ.ធ.អ | ៖ | គណៈកម្មការធានាគុណភាពអប់រំផ្ទៃក្នុង |
| គ.ទ.ផ | ៖ | គណៈកម្មការទំនាក់ទំនង និងផ្សព្វផ្សាយ |
| គ.ន.ប្រ | ៖ | គណៈកម្មការនានាក្នុងការប្រឡង |
| ឆ.ម | ៖ | ឆ្នាំសិក្សាមូលដ្ឋាន |
| ធ.អ | ៖ | ការិយាល័យធានាគុណភាពអប់រំផ្ទៃក្នុង |
| បរិ. | ៖ | បរិញ្ញាបត្រ |
| ប.ណ | ៖ | បណ្ណាល័យ |
| ពណ | ៖ | ក្រសួងពាណិជ្ជកម្ម |
| ម. | ៖ | មហាវិទ្យាល័យ |
| ម.ស.ស | ៖ | មហាវិទ្យាល័យសុខភាពសាធារណៈ |
| ម.វ.ស | ៖ | មហាវិទ្យាល័យវិស្វកម្ម និងស្ថាបត្យកម្ម |
| ម.គ.ព.ទ | ៖ | មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ |
| ម.វ.ប | ៖ | មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា |
| ម.ម.ភ | ៖ | មហាវិទ្យាល័យមនុស្សសាស្ត្រ និងភាសាបរទេស |
| ម.ស.ន | ៖ | មហាវិទ្យាល័យសង្គមសាស្ត្រ និងនីតិសាស្ត្រ |
| ម.ក.សិ | ៖ | មហាវិទ្យាល័យកសិកម្ម |
| ម.ស.ឧ.ន | ៖ | មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីឧត្តមភាព និងនវានុវត្តន៍ |
| ស.អ. | ៖ | សាកលវិទ្យាល័យអង្គរ |
| សខល | ៖ | ក្រសួងសុខាភិបាល |
| ស.ដ្ឋាន | ៖ | សាកលវិទ្យាធិការដ្ឋាន |
| ស.ប្រ.ប | ៖ | ការិយាល័យកិច្ចសហប្រតិបត្តិការ និងបច្ចេកវិទ្យា |
| ស.ក.ប្រ | ៖ | ការិយាល័យសិក្សា និងកិច្ចការប្រឡង |
| អយក. | ៖ | ក្រសួងអប់រំ យុវជន និងកីឡា |
| អនុ.វ.ស.ន | ៖ | អនុគណៈកម្មការវាយតម្លៃការការពារសារណា/និក្ខេបបទ |
| ឧស. | ៖ | ឧត្តមសិក្សា |

## លទ្ធផលសំខាន់ៗ និងបញ្ហាប្រឈមឆ្នាំ ២០២០-២០២១

ក្រោយកំណែទម្រង់ ស.អ. បាននិងកំពុងបណ្ដុះបណ្ដាលនិស្សិតកម្រិតបរិញ្ញាបត្ររងចំនួន ២ជំនាញ បរិញ្ញាបត្រចំនួន ៧ជំនាញ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១ជំនាញ ដែលមាននិស្សិតកំពុងសិក្សាចំនួន ៥៥៩នាក់ ក្នុងនោះមហាវិទ្យាល័យសុខភាពសាធារណៈ (ម.ស.ស)ចំនួន ២៩៦នាក់ មហាវិទ្យាល័យវិស្វកម្ម និងស្ថាបត្យកម្ម(ម.វ.ស)ចំនួន ៦៥នាក់ មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្មនិងទេសចរណ៍(ម.គ.ព.ទ) ចំនួន ៧៨នាក់ មហាវិទ្យាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា(ម.វ.ប) ចំនួន ១៥នាក់ មហាវិទ្យាល័យមនុស្សសាស្ត្រនិងភាសាបរទេស(ម.ម.ភ)ចំនួន ០៦នាក់ ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន (ធ.ម) ចំនួន ៧៥នាក់ និងបរិញ្ញាបត្រជាន់ខ្ពស់មុខជំនាញគ្រប់គ្រងពាណិជ្ជកម្មចំនួន ២៤នាក់។

សម្រាប់រយៈពេល ៤ឆ្នាំចុងក្រោយ ស.អ. បានអភិវឌ្ឍ និងបន្តកំណើនប្រកបដោយទំនុកចិត្តខ្ពស់ជាក់ស្តែងសម្រាប់ឆ្នាំ២០២០-២០២១ ទោះជាមានការរងផលប៉ះពាល់ពីបរិបទកូវីដ-១៩ និងបរិការណ៍ពាក់ព័ន្ធក្ដីក៏និន្នាការកំណើនមានដូចតទៅ ៖ បុគ្គលិកកើនឡើងចំនួន ៧០% គ្រូបង្រៀនចំនួន ៣៦% និស្សិតចំនួន ៦៥% និងក្រៅពីនេះ ដៃគូអភិវឌ្ឍន៍មានចំនួន ៣% (សូមមើលតារាងទី១)។

**តារាងទី០១៖ និន្នាការនៃចំនួនបុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និស្សិត និងដៃគូអភិវឌ្ឍន៍**

| | ចំនួន(នាក់) | | | | ផលធៀប(ភាគរយ) | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
| បុគ្គលិក | ១៨ | ២៣ | ៣៣ | ៥៦ | - | ២៨ | ៤៣ | ៧០ |
| សាស្ត្រាចារ្យ | ៣៨ | ៨២ | ១៦០ | ២១៨ | - | ១១៦ | ៩៥ | ៣៦ |
| និស្សិត | ១៥៥ | ២១៧ | ៣០៥ | ៥០៤ | - | ៤០ | ៤០ | ៦៥ |
| ដៃគូអភិវឌ្ឍន៍ | ៥ | ៥ | ៣២ | ៣៣ | - | - | ៥៤០ | ៣ |

ទោះបីជាលទ្ធផលនៃការអនុវត្តការងារក្នុងឆ្នាំសិក្សាកន្លងទៅមានភាពជោគជ័យមួយកម្រិតក៏ដោយ ក៏ស.អ. បានជួបនូវបញ្ហាប្រឈមដូចតទៅ ៖

- បុគ្គលិករដ្ឋបាលប្រឈមនឹងការខ្វះខាតក្នុងការគ្រប់គ្រង និងការយោគយល់
- ក្របខ័ណ្ឌគុណវុឌ្ឍិរបស់បុគ្គលិករដ្ឋបាលមិនទាន់ឆ្លើយតបគ្រប់ជ្រុងជ្រោយតាមស្តង់ដាគុណវុឌ្ឍិជាតិកម្ពុជា
- ការចូលរួម និងអភិវឌ្ឍពីភាគី គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិតនៅមានកម្រិត
- កិត្យានុភាព និងកេរ្តិ៍ឈ្មោះរបស់ ស.អ. ក្នុងក្រសែភ្នែកអ្នកសិក្សា អ្នកស្រាវជ្រាវ ព្រមទាំងសាធារណជនមួយចំនួននៅមានភាពអវិជ្ជមាន និង
- ស្តង់ដា និងការវាយតម្លៃគុណភាពអប់រំត្រូវបានអនុវត្តមានកម្រិត។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យអង្គរ**

លេខ ............................... ស.អ.

# សេចក្តីសម្រេច
# ប្រធានក្រុមប្រឹក្សាភិបាល

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យអង្គរ (ស.អ.)
- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យ ក្នុងវិស័យសុខាភិបាលបានឃើញប្រកាសលេខ ១៤៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០០៧ ស្តីពីលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យលម្អិតសម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា
- បានឃើញសេចក្តីសម្រេចលេខ ០១១/១៩ ស.អ. ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ស្តីពីការ តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃ ស.អ.
- យោងផែនការយុទ្ធសាស្ត្រឆ្នាំ២០១៨-២០២៣ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ ដែលមានឈ្មោះ ថា «វិថីអេយូទំនោរជោគជ័យ»
- បានឃើញសំណើរបស់សាកលវិទ្យាធិការ។

## សម្រេចឱ្យប្រើប្រាស់

ផែនការប្រតិបត្តិឆ្នាំ ២០២១-២០២២ ដែលមានឈ្មោះថា «យន្តការជំរុញ និងគ្រប់គ្រងហានិភ័យក្នុង បរិបទក្រោយកូវីដ-១៩» ដែលប្រជុំអនុម័តដោយគណៈកម្មការប្រតិបត្តិរបស់ ស.អ. កាលពីថ្ងៃព្រហស្បតិ៍ ៦រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ហើយមាន ៨ជំពូក ព្រម ទាំងមានខ្លឹមសារទាំងស្រុងដូចតទៅ ៖

# សេចក្តីសម្រេចដាក់ឱ្យប្រើប្រាស់
# ផែនការប្រតិបត្តិឆ្នាំ ២០២១-២០២២

# ជំពូក ១

## សេចក្តីផ្តើម

សាកលវិទ្យាល័យអង្គរ (ស.អ.) ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២៨ អនក្រ. បក. ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៤ ។ អាសយដ្ឋាន ស.អ. កូដប្រៃសណីយ៍ ៖ ១៧១២០៦ ផ្លូវបុរីសៀងណាំ ភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប មានលេខទូរស័ព្ទ៖០៧៨ ៣៨៨ ៨៨២/០៧០ ៨៥ ៣៥ ៣៧ អ៊ីមែល៖ rector@angkor.edu.kh/info@angkor.edu.kh វេបសាយ៖ angkor.edu.kh និងតេឡេក្រាមផ្លូវការ https://t.me/angkoruniversiti ឆាណែលយូធូប៖ https://www.youtube.com/channel/UC5dswiqIVnZ9ixnm7Ny513g និងផេកហ្វេសប៊ុក៖ Angkor University។ ក្រៅពីនេះ ក៏មានការទទួលស្គាល់ពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំយុវជននិងកីឡា (អយក.) និង ក្រសួងសុខាភិបាល (សខល) ព្រមទាំង បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម (ពណ) និងមានអត្តលេខបង់ពន្ធត្រឹមត្រូវពីអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានបង្ហាញខាងក្រោម ៖

- អនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការទទួលស្គាល់ ស.អ.
- ប្រកាសលេខ ១០៤៦ អយក.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៦ របស់ អយក. ស្តីពីការទទួលស្គាល់ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅ ស.អ.
- ប្រកាសលេខ ២៦៥៦ អយក.ប្រក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ របស់ អយក. ស្តីពីការទទួលស្គាល់មុខជំនាញថ្មីនៅ ស.អ. លើមុខជំនាញគ្រប់គ្រងពាណិជ្ជកម្មបង្រៀនជាភាសាអង់គ្លេសនិងកូរ៉េ មុខជំនាញភាសាកូរ៉េ មុខជំនាញគិលានុបដ្ឋាក (កម្រិតបរិញ្ញាបត្ររង) និងមុខជំនាញធ្មប (កម្រិតបរិញ្ញាបត្ររង)
- ប្រកាសលេខ ៣៦២៥ អយក.ឧស. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ របស់ អយក. ស្តីពីការទទួលស្គាល់មហាវិទ្យាល័យសុខភាពសាធារណៈ នៅ ស.អ.
- លិខិត លេខ ១៧៩៨ អយក.ឧស. ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៤ របស់ អយក. ស្តីពីការទទួលស្គាល់មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្មនិងទេសចរណ៍ វិទ្យាសាស្ត្រនិង-បច្ចេកវិទ្យា សង្គមសាស្ត្រនិងនីតិសាស្ត្រ កសិកម្ម និងមុខជំនាញភាសាអង់គ្លេសនៅ ស.អ.
- ប្រកាសលេខ ១៧៦៧ អយក.ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ អយក. ស្តីពីការទទួលស្គាល់មហាវិទ្យាល័យវិស្វកម្ម និងស្ថាបត្យកម្មនៅ ស.អ.
- វិញ្ញាបនបត្របញ្ជាក់ លេខ MOC- ៦៥៩៧៦៤១៦ ពណ.ចបព ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ ពណ ស្តីពីការចុះឈ្មោះបញ្ជីពាណិជ្ជកម្មរបស់ ស.អ.
- លិខិតលេខ ៤៣៨ អបស.អធម ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យបើកដំណើរការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្របែបពាក់កណ្តាលពេលនៅ ស.អ.
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារលេខ PTM២០២១០២៨៥៧៤ អពដ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីអាករលើតម្លៃបន្ថែម-អតបរបស់ ស.អ.

– លិខិតលេខ ១៦៦ អបស.អធម ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្ដីពីការអនុញ្ញាតជ្រើសរើសនិស្សិតចូលរៀនថ្នាក់បរិញ្ញាបត្របែបពាក់កណ្ដាលពេលជំនាន់ទី២ សម្រាប់ឆ្នាំសិក្សា ២០២១-២០២២ នៅ ស.អ.

ស.អ. មានអគារផ្ទាល់ខ្លួនដែលជាទ្រព្យរបស់ស្ថាបនិក ឯកឧត្តមអ្នកឧកញ៉ាបណ្ឌិត សៀង ណាំ ដែលបច្ចុប្បន្នជាប្រធានក្រុមប្រឹក្សាភិបាល។ អគារ ស.អ. សាងសង់លើផ្ទៃដីសរុបទំហំ ១៥,០០០ម$^{២}$ ហើយស្ថិតតាមបណ្ដោយផ្លូវ សៀង ណាំ ជាប់នឹងចំណតរថយន្តក្រុងប៉ែកខាងកើតនៃទីក្រុងសៀមរាប។ នៅពីមុខ ស.អ. មានសួនច្បារបៃតងដែលមានផ្លូវដើរស្របតាមវិថី សៀង ណាំ ហើយរំលេចដោយស្លាកសាកលវិទ្យាល័យដ៏ស្រស់ស្អាតងាយស្រួលស្វែងរក និងទាក់ទាញអ្នកសិក្សាទូទៅ និងសាធារណជន។ នៅលើរបងផ្នែកខាងមុខមានបំពាក់ផ្ទាំងបេនណឺរូបភាពដែលបង្ហាញពីជំនាញ និងសកម្មភាពសិក្សារបស់និស្សិតក្នុងមហាវិទ្យាល័យនីមួយៗ។ ក្រៅពីនេះ ស.អ. មានបណ្ដុះបណ្ដាលនិស្សិតកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ស្របតាមមុខជំនាញដូចមានបង្ហាញក្នុងតារាងទី២។

**តារាងទី០២ ៖ មុខជំនាញ និងកម្រិតបណ្ដុះបណ្ដាលតាមមហាវិទ្យាល័យ**

<table>
<tr><th rowspan="2">ល.រ</th><th rowspan="2">មហាវិទ្យាល័យ<br>Faculties</th><th rowspan="2">មុខជំនាញ<br>Majors</th><th rowspan="2">ច្បាប់អនុញ្ញាត<br>Licenses</th><th colspan="3">កម្រិតបណ្ដុះបណ្ដាល<br>Level of Education</th></tr>
<tr><th>បរិ.រង<br>Ass</th><th>បរិ<br>B.A</th><th>ជាន់ខ្ពស់<br>M.A</th></tr>
<tr><td rowspan="4">១</td><td rowspan="4">ម.ស.ស<br>Public Health</td><td>គិលានុបដ្ឋាក<br>Nursing</td><td rowspan="2">ប្រកាសលេខ ២៦៥៦ អយក. ប្រក ២១ តុលា ២០១៥<br>Prakas No 2656 AYK.BrK 21 Oct 2015</td><td rowspan="2">✓</td><td rowspan="2">x</td><td rowspan="2">x</td></tr>
<tr><td>ឆ្មប<br>Midwifery</td></tr>
<tr><td rowspan="2">គិលានុបដ្ឋាកបែបពាក់កណ្ដាលពេល<br>Bachelor of science in Nursing</td><td>លិខិតលេខ ៤៣៨ អបស.អធម ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០២០<br>Letter No 438 ABS.ATM 01 December 2020</td><td rowspan="2">x</td><td rowspan="2">✓</td><td rowspan="2">x</td></tr>
<tr><td>លិខិតលេខ ១៦៦ អបស.អធម ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ ២០២១<br>Letter No 166 ABS.ATM 20 August 2021</td></tr>
<tr><td rowspan="2">២</td><td rowspan="2">ម.គ.ព.ទ<br>Business Administration and Tourism</td><td>គណនេយ្យ<br>Accounting</td><td rowspan="2"></td><td>✓</td><td>✓</td><td>✓</td></tr>
<tr><td>ធនាគារ និងហិរញ្ញវត្ថុ<br>Finance and Baking</td><td>✓</td><td>✓</td><td>✓</td></tr>
</table>

| ល.រ | មហាវិទ្យាល័យ<br>Faculties | មុខជំនាញ<br>Majors | ច្បាប់អនុញ្ញាត<br>Licenses | កម្រិតបណ្ដុះបណ្ដាល<br>Level of Education | | |
|---|---|---|---|---|---|---|
| | | | | បរិ.រង<br>Ass | បរិ<br>B.A | ជាន់ខ្ពស់<br>M.A |
| | | ទីផ្សារ<br>Marketing | លិខិតលេខ<br>១៧៩៨<br>អយក.ឧស<br>៥ កក្កដា ២០០៤<br>Letter No 1798<br>AYK.DS<br>5 July 2005 | ✓ | ✓ | ✓ |
| | | គ្រប់គ្រងពាណិជ្ជកម្ម<br>Business Management | | ✓ | ✓ | ✓ |
| | | កុំព្យូទ័រពាណិជ្ជកម្ម<br>Business Computer | | ✓ | ✓ | ✓ |
| | | គ្រប់គ្រងធនធានមនុស្ស<br>Human Resource Management | | ✓ | ✓ | ✓ |
| | | គ្រប់គ្រងប្រព័ន្ធព័ត៌មាន<br>Information System Management | | ✓ | ✓ | ✓ |
| | | គ្រប់គ្រងសណ្ឋាគារ និង ទេសចរណ៍<br>Hotel and Tourism Management | | ✓ | ✓ | ✓ |
| | | គ្រប់គ្រងពាណិជ្ជកម្ម បង្រៀនជាភាសាអង់គ្លេស និងកូរ៉េ<br>Business Management in English and Korean Languages | ប្រកាសលេខ<br>២៦៥៦<br>អយក. ប្រក<br>២១ តុលា ២០១៥<br>Prakas No 2656<br>AYK.BrK<br>21 Oct 2015 | ✓ | ✓ | |
| ៣ | ម.ម.ភ<br>Humanities and Foreign Languages | ភាសាអង់គ្លេស<br>English Language | លិខិតលេខ<br>១៧៩៨<br>អយក.ឧស<br>៥ កក្កដា ២០០៤<br>Letter No 1798<br>AYK.DS<br>5 July 2005 | ✓ | ✓ | |
| | | ភាសាកូរ៉េ<br>Korean Language | ប្រកាសលេខ<br>២៦៥៦<br>អយក. ប្រក<br>២១ តុលា ២០១៥<br>Prakas No 2656<br>AYK.BrK<br>21 Oct 2015 | ✓ | ✓ | |
| ៤ | ម.វ.ប<br>Science and Technology | វិទ្យាសាស្ត្រកុំព្យូទ័រ<br>Computer Science | លិខិតលេខ<br>១៧៩៨<br>អយក.ឧស | | ✓ | ✓ |
| | | ព័ត៌មានវិទ្យា<br>Information Technology | | | ✓ | ✓ |

| ល.រ | មហាវិទ្យាល័យ<br>Faculties | មុខជំនាញ<br>Majors | ច្បាប់អនុញ្ញាត<br>Licenses | កម្រិតបណ្ដុះបណ្ដាល<br>Level of Education | | |
|---|---|---|---|---|---|---|
| | | | | បរិ.រង<br>Ass | បរិ<br>B.A | ជាន់ខ្ពស់<br>M.A |
| | | | ៥ កក្កដា ២០០៤<br>Letter No 1798<br>AYK.DS<br>5 July 2005 | | | |
| ៥ | ម.ស.ន<br>Sociology and Law | នីតិសាធារណៈ<br>Public Law | លិខិតលេខ<br>១៧៩៨<br>អយក.ឧស<br>៥ កក្កដា ២០០៤<br>Letter No 1798<br>AYK.DS<br>5 July 2005 | | ✓ | ✓ |
| | | នីតិឯកជន<br>Private Law | | | ✓ | ✓ |
| | | សេដ្ឋកិច្ច<br>Economics | | | ✓ | ✓ |
| | | វិទ្យាសាស្ត្រនយោបាយ និងទំនាក់ទំនងអន្តរជាតិ<br>Political Science and International Relations | | | ✓ | ✓ |
| ៦ | ម.ក.សិ<br>Agriculture | ក្សេត្រសាស្ត្រ<br>Agronomy | លិខិតលេខ<br>១៧៩៨<br>អយក.ឧស<br>៥ កក្កដា ២០០៤<br>Letter No 1798<br>AYK.DS<br>5 July 2005 | ✓ | ✓ | |
| | | អភិវឌ្ឍន៍ជនបទ<br>Rural Development | | ✓ | ✓ | |
| ៧ | ម.វ.ស<br>Engineering and Architecture | សំណង់ស៊ីវិល<br>Civil Engineering | ប្រកាសលេខ<br>១៧៦៧ អយក.ប្រ<br>៨ វិច្ឆិកា ២០១៩<br>Prakas No 1767<br>AYK.BrK<br>08 August 2019 | | ✓ | |
| | | អគ្គិសនី និងអេឡិចត្រូនិច<br>Electricity and Electronics | | | ✓ | |
| | | ស្ថាបត្យកម្ម<br>Architecture | | | ✓ | |
| | | រចនាផ្ទៃកខាងក្នុង<br>Interior Design | | | ✓ | |

ក្រៅពីនេះ ស.អ. បានផ្តល់ឱកាសដល់ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង បុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិតដើម្បីអភិវឌ្ឍន៍សមត្ថភាពតាមរយៈការចូលរួមសកម្មភាពជាច្រើនដូចជា ការចុះសហគមន៍ ការបោះជំរំ សិក្ខាសាលាជាតិនិងអន្តរជាតិតាមប្រព័ន្ធអនឡាញ។

យោងតាមនិន្នាការបម្រែបម្រួលរបស់ ស.អ. រយៈពេល ៤ឆ្នាំ ចុងក្រោយ ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសិក្សា២០២១-២០២២ ក្នុងគោលបំណងដើម្បី៖

- បន្តរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងរួម និងដោយឡែកដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យ និងបេសកកម្មរបស់ខ្លួន

- បន្តជ្រើសរើសវាយតម្លៃ លើកទឹកចិត្ត និងអភិវឌ្ឍក្រុមប្រឹក្សាភិបាល គណៈប្រតិបត្តិ ស្របតាមអភិបាលកិច្ច និងគោលការណ៍គ្រប់គ្រងដែលមានស្រាប់
- បន្តជំរុញ និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង បុគ្គលិករដ្ឋបាលធ្វើការអភិវឌ្ឍសមត្ថភាព និងបង្កើនគុណវុឌ្ឍិរបស់ខ្លួនពេញមួយជីវិត
- បន្តជំរុញថ្នាក់ដឹកនាំ គណៈគ្រប់គ្រង បុគ្គលិករដ្ឋបាលអនុវត្តភារកិច្ច ប្រកបដោយភាពទទួលខុសត្រូវនិងភាពចុះសម្រុងគ្នាបំផុត
- ធ្វើការវាយតម្លៃការអនុវត្តផែនការ និងលើកទិសដៅស្របតាមចក្ខុវិស័យ និងបេសកកម្មរបស់ ស.អ.
- បន្តពង្រឹងការគ្រប់គ្រង និងប្រតិបត្តិការប្រព័ន្ធគណនេយ្យអន្តរជាតិនៃកម្ពុជា ប្រកបដោយគណនេយ្យភាព
- បន្តពិនិត្យ និងធ្វើសវនកម្មផ្ទៃក្នុង ស្របតាមអភិបាលកិច្ច និងគោលការណ៍គ្រប់គ្រងដែលបានចែង
- ជំរុញការសិក្សាស្រាវជ្រាវអំពីបញ្ហាប្រឈមរបស់និស្សិតបញ្ចប់ការសិក្សានៃមុខជំនាញនីមួយៗ ព្រមទាំងស្រាវជ្រាវអំពីទីផ្សារការងារពីសហគ្រិនជាតិ និងអន្តរជាតិ
- បង្កើនបរិមាណឯកសារយោងដែលត្រូវតម្កល់នៅបណ្ណាល័យស្របតាមកម្មវិធីសិក្សា
- បន្តធ្វើការវាយតម្លៃ និងតាមដានលើការអនុវត្តផែនការជ្រើសរើសគ្រូបង្រៀន/សាស្ត្រាចារ្យប្រចាំឆមាស/ឆមាស/ឆ្នាំ
- បន្តធ្វើការប្រៀបធៀបអត្រាគ្រូបង្រៀននិងនិស្សិត គ្រូបង្រៀនពេញម៉ោងនិងវេលាការ ស្របតាមផែនការដែលបានកំណត់
- បន្តជំរុញគ្រូបង្រៀនដើម្បីធ្វើការអភិវឌ្ឍសមត្ថភាព ចូលរួមការងារស្រាវជ្រាវ កិច្ចការតម្រង់ទិសអភិវឌ្ឍសហគមន៍ និងជំរុញការងារសង្គម ព្រមទាំងការពារកេរ្តិ៍ឈ្មោះរបស់សាកលវិទ្យាល័យ
- បន្តសិក្សា និងតាមដានអំពីអត្រាបោះបង់ការបង្រៀន នៅគ្រប់មហាវិទ្យាល័យ
- បន្តវាយតម្លៃ និងពិនិត្យការអនុវត្តផែនការអភិវឌ្ឍធនធានរូបវន្តរយៈពេលខ្លី និងវែង
- បន្តផ្សព្វផ្សាយសេចក្តីណែនាំអំពី សុវត្ថិភាព និងសន្តិសុខដល់គណៈគ្រប់គ្រង បុគ្គលិក គ្រូបង្រៀន និងនិស្សិត
- បន្តផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការថែរក្សាការពារទិន្នន័យ និងសម្ភារអេឡិចត្រូនិកដល់គណៈគ្រប់គ្រង បុគ្គលិក គ្រូបង្រៀន និងនិស្សិត
- ជំរុញការអនុវត្តផែនការផ្សព្វផ្សាយ ការចុះឈ្មោះចូលរៀន ការប្រឡងបញ្ចប់ការសិក្សា និងការការពារសារណា/និក្ខេបបទ ប្រកបដោយប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រនិងនវានុវត្តន៍ ក្រុមប្រឹក្សាអប់រំនិងបណ្តុះ-បណ្តាល និង ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បន្តជំរុញនិស្សិតចូលរួមក្នុងកិច្ចការស្រាវជ្រាវ កម្មវិធីអប់រំបន្ថែម ការចូលរួមកិច្ចការសហគមន៍ ការចុះអនុវត្តផ្ទាល់ ព្រមទាំងការងារស្ម័គ្រចិត្តដទៃៗទៀត

- បន្តប្រឹក្សានិស្សិតរៀនខ្សោយ និស្សិតមានបំណងបោះបង់ការសិក្សា ព្រមទាំងទទួលសំណូមពរនានារបស់ពួកគេសម្រាប់ដោះស្រាយ
- បន្តប្រឹក្សាអាជីពការងារ បញ្ហាផ្ទាល់ខ្លួន ដើម្បីក្លាយជាយុវជនជោគជ័យ
- បន្តជ្រោមជ្រែង និងផ្សារភ្ជាប់និស្សិតទៅជាមួយនឹងក្លឹបនិស្សិតស្ម័គ្រចិត្ត ក៏ដូចជាក្លឹបអតីតនិស្សិត
- បន្តផ្សព្វផ្សាយផែនការស្រាវជ្រាវ ព្រមទាំងជំរុញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ
- បន្តស្មារតី និងអនុវត្តកម្មវិធីផ្លាស់ប្តូរវប្បធម៌ ព្រឹត្តិការណ៍នានា ព្រមទាំងកម្មវិធីប្រកួតប្រជែងអំណាន
- ជំរុញការលើកទឹកចិត្តជារូបី និងអរូបីដល់បុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិត
- ធ្វើការស្រាវជ្រាវអំពីលទ្ធផលសិក្សារបស់និស្សិតប្រចាំឆ្នាំ ដើម្បីជាធាតុចូលសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សា
- បន្តបង្កើនការបោះពុម្ពផ្សាយទាំងអត្ថបទស្រាវជ្រាវ និងសៀវភៅកិច្ចការរដ្ឋបាលនានារបស់ ស.អ.
- ជំរុញបង្កើនការចុះ MOU និង MOA ជាមួយដៃគូជាតិ និងអន្តរជាតិ
- បន្តបង្កើនសកម្មភាពទស្សនកិច្ចសិក្សា និងផ្លាស់ប្តូរបទពិសោធន៍នៅក្នុងស្រុក និងបរទេស
- បន្តផ្តល់ និងផ្សព្វផ្សាយកម្មវិធីអាហារូបករណ៍ ដល់អ្នកសិក្សាទូទៅ
- សិក្សាស្រាវជ្រាវអំពីឥរិយាបថរបស់និស្សិតអាហារូបករណ៍
- បន្តស្វែងរកដៃគូអភិវឌ្ឍន៍សម្រាប់ធ្វើការស្រាវជ្រាវរួមគ្នា
- បន្តការពិនិត្យតាមដាន និងវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង
- បន្តជំរុញការទទួលស្គាល់គុណភាពអប់រំពីស្ថាប័នខាងក្រៅ។

## ជំពូក ២
## ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងអត្តសញ្ញាណឡូហ្គោ

ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងគោលដៅរបស់ ស.អ. ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ២០១៨-២០២៣ និងដោយយោងតាមកំណត់ហេតុអង្គប្រជុំ លេខ ០២០១-១/២០ ស.អ. ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ ស្តីពីការកែសម្រួល ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងគោលដៅ ដូចខាងក្រោម ៖

**១.១.១- ចក្ខុវិស័យ**

ស.អ. នឹងក្លាយជាគ្រឹះស្ថានអប់រំដែលបង្កើតកម្លាំងពលកម្មអាជីព សម្រាប់តម្រូវការទីផ្សារការងារកម្ពុជា និងអាស៊ានប្រកបដោយភាពជាអ្នកដឹកនាំ ភាពច្នៃប្រឌិត និងនវានុវត្តន៍ ស្របតាមបរិបទសាកលភាវូបនីយកម្ម។

**១.១.២- បេសកកម្ម**

ដើម្បីសម្រេចបានតាមចក្ខុវិស័យដែលបានកំណត់សាកលវិទ្យាល័យបានដាក់ចេញនូវបេសកកម្មចំនួន០៣ ចំណុចដូចខាងក្រោម៖

- បណ្តុះបណ្តាលជំនាញផ្សេងៗ ស្របតាមតម្រូវការទីផ្សារការងារជាតិ និងអន្តរជាតិ
- ផលិតធនធានមនុស្សប្រកបដោយគុណភាព និងឧត្តមភាព
- ផ្តល់បរិយាកាសនៃការអប់រំ ការសិក្សា ការស្រាវជ្រាវ និងការអភិវឌ្ឍពេញមួយជីវិត។

**១.១.៣- តម្លៃស្នូល**

ការធានានូវគុណភាពត្រូវកើតចេញពីឆន្ទៈ កិច្ចខិតខំប្រឹងប្រែង និងចក្ខុវិស័យវែងឆ្ងាយដើម្បីជាមូលដ្ឋានក្នុងការធ្វើឱ្យសម្រេចបាននូវគុណភាព និងភាពជាអ្នកដឹកនាំ ដូចនេះសាកលវិទ្យាល័យដាក់ចេញនូវគុណតម្លៃដូចខាងក្រោម ៖

**ក. គុណភាព**/Quality

- សុច្ចរិតភាព/Integrity
  - ភាពជឿជាក់/Reliability
  - ភាពស្មោះត្រង់/Honesty
  - ភាពទទួលខុសត្រូវ/Responsibility
- នវានុវត្តន៍/Innovation
  - ការគិតដោយភាពច្នៃប្រឌិត/Creative Thinking
  - ការបង្កើតឱកាស/Opportunity Creation
  - និរន្តរភាព/Sustainability
- ការចូលរួមសកម្មភាពសង្គម/Social Engagement
  - គណនេយ្យភាព/Accountability
  - ការប្តេជ្ញាចិត្ត/Commitment
  - ការស្ម័គ្រចិត្ត/Volunteering

**ខ. ពុទ្ធិ**/Knowledge

- ភាពរីកចម្រើន និងការអភិវឌ្ឍ/Growth and Development
- ការទំនាក់ទំនងល្អក្នុងគ្រួសារ និងសង្គម/Good Relationship in family and Society
- សុខភាព សុវត្ថិភាព និងគុណភាពជីវិត/Health, Safety, and Quality of life

**គ. សីលធម៌**/Morality

- ភាពចុះសម្រុងគ្នា/Harmony
- ភាពថ្លៃថ្នូរក្នុងសង្គម/Dignity in society
- ស្មារតី និងមនសិការស្នេហាជាតិ/National Conscience and Spirit

អត្ថន័យឡូហ្គោរបស់ ស.អ. ត្រូវបានកំណត់ស្របតាមកំណត់ហេតុអង្គប្រជុំលេខ ០២២០/១៧ ស.អ. ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការអនុម័ត អត្ថន័យឡូហ្គោ ចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងគោលដៅនៃ ស.អ. ដូចតទៅ៖

- រូបអង្គរវត្ត ៖ តំណាងឱ្យប្រភពចំណេះដឹងដែលមិនអាចកាត់ថ្លៃបាន
- ផ្លូវចូលទៅកាន់ប្រាសាទអង្គរវត្ត ៖ សំដៅដល់មាគ៌ាឆ្ពោះទៅរកប្រភពនៃចំណេះដឹង
- រូបក្បាលនាគពណ៌បៃតងខ្ចី ៖ តំណាងឱ្យចំណេះដឹងដែលផ្តល់ឱ្យភាពជោគជ័យ សម្បូររុងរឿង ត្រជាក់ត្រជុំ និងសុខដុមរមនា
- ផ្ទៃមេឃមានពពកសតិចៗ ៖ តំណាងឱ្យចំណេះដឹងដែលប្រកបដោយភាពជាអ្នកដឹកនាំ គ្រប់កាលៈទេសៈ
- ពាក្យ សាកលវិទ្យាល័យអង្គរ ពណ៌ខៀវ ៖ តំណាងឱ្យតម្លៃនៃកម្មវិធីថ្នាក់ជាតិ
- ពាក្យ Angkor University ពណ៌ខៀវ ៖ តំណាងឱ្យការត្រៀមខ្លួនជានិច្ចរបស់ ស.អ. ក្នុងការធ្វើសមាហរណកម្មទៅក្នុងសកលលោក
- រង្វង់មូលព័ទ្ធជុំវិញផ្នែកខាងក្នុង ៖ តំណាងឱ្យសាមគ្គីភាពរវាងនិស្សិតកំពុងសិក្សា និងអតីតនិស្សិត ស.អ.
- រង្វង់មូលព័ទ្ធជុំវិញផ្នែកខាងក្រៅ ៖ តំណាងឱ្យការត្រៀមខ្លួនប្រកួតប្រជែង របស់និស្សិត ស.អ. នៅក្នុងទីផ្សារការងារជាតិ និងអន្តរជាតិ
- ផ្ទៃពណ៌សនៅចន្លោះរង្វង់មូលព័ទ្ធខាងក្នុង និងខាងក្រៅ ៖ តំណាងឱ្យតម្លៃនៃការលះបង់ស្មោះស្ម័គ្រ និងសេចក្តីស្រឡាញ់របស់និស្សិត ស.អ. ក្នុងការបម្រើការងារ តាមផ្នែកនីមួយៗ ស្របតាមជំនាញរបស់ខ្លួននៅគ្រប់កម្រិត និងគ្រប់បរិបទ។

## ជំពូក ៣
# គោលដៅយុទ្ធសាស្ត្រ និងទិសដៅយុទ្ធសាស្ត្រ

## ៣.១. គោលដៅយុទ្ធសាស្ត្រ

សម្រាប់ឆ្នាំ ២០២១-២០២២ ការបន្តការរៀបចំ និងអភិវឌ្ឍប្រព័ន្ធអភិបាលកិច្ចល្អ ថែមទាំងកំណត់យន្តការធានាគុណភាពអប់រំកម្រិតជាតិ ដើម្បីធានាសមត្ថភាពអ្នកសិក្សា និងអ្នកស្រាវជ្រាវឱ្យឆ្លើយតបទៅនឹងទីផ្សារការងារកម្ពុជា និងតំបន់ ជាពិសេសខេត្តសៀមរាប ស.អ. នឹងបន្តដំណើរការអនុវត្តគោលដៅយុទ្ធសាស្ត្រដូចខាងក្រោម ៖

- ការពង្រឹងការគ្រប់គ្រងប្រកបដោយភាពជាអ្នកដឹកនាំ
- ការបង្កើនគុណភាពអប់រំប្រកបដោយនិរន្តរភាព
- ការស្រាវជ្រាវ និងការអភិវឌ្ឍ
- ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការទទួលស្គាល់គុណភាពអប់រំថ្នាក់ជាតិ និងអន្តរជាតិ។

## ៣.២. ទិសដៅយុទ្ធសាស្ត្រ

ដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រខាងលើ ស.អ. បានកំណត់ទិសដៅយុទ្ធសាស្ត្រសំខាន់ៗ ដូចខាងក្រោម ៖

### ៣.២.១- ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចច្បាស់លាស់

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

- ពិនិត្យការអនុវត្តការងារស្របតាមប្រព័ន្ធគ្រប់គ្រងរួម។

### ៣.២.២- ការលើកកម្ពស់សមត្ថភាពបុគ្គលិក និងការលើកទឹកចិត្ត

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

- បង្កើនសមត្ថភាពបុគ្គលិករដ្ឋបាល
- លើកទឹកចិត្តបុគ្គលិកគ្រប់កម្រិត។

### ៣.២.៣- ការរៀបចំយន្តការដឹកនាំគ្រប់គ្រង និងប្រតិបត្តិការច្បាស់លាស់

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- កំណត់យន្តការដឹកនាំ និងគ្រប់គ្រង
- កំណត់ប្រព័ន្ធប្រតិបត្តិការ

### ៣.២.៤- ការកំណត់ប្រព័ន្ធតាមដាន និងវាយតម្លៃជាក់លាក់

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- កំណត់ប្រព័ន្ធតាមដានការងារ
- វាយតម្លៃការងារ។

**៣.២.៥- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- រៀបចំផែនការហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- បន្តធ្វើសង្គតិភាពប្រព័ន្ធគណនេយ្យ ស.អ. ទៅនឹងស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ ២០២១-២០២២ ស្របតាមគោលការណ៍គណនេយ្យ ស.អ.

**៣.២.៦- ការអភិវឌ្ឍកម្មវិធីសិក្សាជាតិ និងអន្តរជាតិ**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បកប្រែមុខវិជ្ជាក្នុងកម្មវិធីសិក្សាពីភាសាអង់គ្លេសមកភាសាខ្មែរគ្រប់កម្រិត
- បញ្ចូលកូដមុខវិជ្ជាក្នុងកម្មវិធីសិក្សាគ្រប់កម្រិត
- ចងក្រង និងបោះពុម្ពសៀវភៅកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងថ្នាក់បរិញ្ញាបត្រ
- ស្រាវជ្រាវអំពីភាពពេញចិត្តលើកម្មវិធីសិក្សាដែលកំពុងបណ្តុះបណ្តាល
- បន្តអភិវឌ្ឍសៀវភៅគោល តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល
- បន្តស្រាវជ្រាវសៀវភៅយោងបន្ថែម តាមមុខជំនាញដែលកំពុងបណ្តុះបណ្តាល
- ប្រជុំផ្សព្វផ្សាយកម្មវិធីសិក្សា។

**៣.២.៧- ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន/សាស្ត្រាចារ្យ**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បន្តធ្វើការស្ទង់មតិគ្រូបង្រៀន/សាស្ត្រាចារ្យ អំពីការពេញចិត្តចំពោះ ស.អ.
- បន្តលើកទឹកចិត្តគ្រូបង្រៀន/សាស្ត្រាចារ្យ
- រៀបចំសិក្ខាសាលាស្តីពីវិធីសាស្ត្របង្រៀន

**៣.២.៨- ការអភិវឌ្ឍសម្ភាររូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ពិនិត្យ វាយតម្លៃសម្ភាររូបវន្តសម្រាប់ការសិក្សា និងស្រាវជ្រាវ
- បង្កើននិងអភិវឌ្ឍសំណង់អគារថ្មី
- អភិវឌ្ឍសម្ភាររូបវន្តសម្រាប់មហាវិទ្យាល័យសុខភាពសាធារណៈ
- អភិវឌ្ឍសម្ភាររូបវន្តសម្រាប់មហាវិទ្យាល័យវិស្វកម្ម និងស្ថាបត្យកម្ម

- អភិវឌ្ឍសម្ភារបរិក្ខារវប្បនិធិ សម្រាប់មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- អភិវឌ្ឍសម្ភារបរិក្ខារវប្បនិធិ សម្រាប់មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- អភិវឌ្ឍសម្ភារបរិក្ខារវប្បនិធិ សម្រាប់មហាវិទ្យាល័យសង្គមសាស្ត្រ និងនីតិសាស្ត្រ

**៣.២.៩- ការលើកកម្ពស់គុណភាពសិក្សា និងការស្រាវជ្រាវ**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ផ្សព្វផ្សាយ និងតម្រង់ទិសអំពីបទបញ្ញាផ្ទៃក្នុងនិស្សិតគ្រប់កម្រិត
- ជ្រើសរើសនិស្សិតចុះឈ្មោះចូលរៀន
- ពង្រឹងគុណភាពសិក្សា និងចំនួនបញ្ចប់របស់និស្សិត
- បង្កើនកម្មវិធីអភិវឌ្ឍសមត្ថភាព ការសិក្សា និងស្រាវជ្រាវបន្ថែមលើកម្មវិធីសិក្សាដែលមាននៅក្នុងកម្រិតសិក្សារបស់ខ្លួន។

**៣.២.១០- ការបង្កើនគុណភាពផ្តល់សេវាកម្មនិស្សិត**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បង្កើនតម្លាភាពក្នុងការផ្តល់ព័ត៌មានអំពីសកម្មភាពបណ្តុះបណ្តាល និងសេវាគាំទ្រ
- ជួយសម្របសម្រួលដល់និស្សិតក្នុងសកម្មភាពស្ម័គ្រចិត្ត និងកិច្ចការសង្គម។

**៣.២.១១- ការរៀបចំការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍសាកលវិទ្យាល័យ**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- រៀបចំយន្តការស្រាវជ្រាវគោលការណ៍ និងនីតិវិធីស្រាវជ្រាវរបស់ ស.អ.
- រៀបចំយុទ្ធនាការបង្កើនគម្រោងស្រាវជ្រាវ។

**៣.២.១២- ការបង្កើតវប្បធម៌ស្រាវជ្រាវ និងអំណាននិស្សិត**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បង្កើតកម្មវិធីប្រកួតប្រជែងស្នាដៃរបស់និស្សិត។

**៣.២.១៣- ការបង្កើតវប្បធម៌ស្រាវជ្រាវរបស់បុគ្គលិក និងគ្រូបង្រៀន/សាស្ត្រាចារ្យ**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- រៀបចំមូលនិធិស្រាវជ្រាវ
- ជំរុញបុគ្គលិក និងគ្រូបង្រៀនចូលរួមស្រាវជ្រាវ។

**៣.២.១៤- ការធ្វើទំនើបកម្ម និងនវានុវត្តឯកសារសម្រាប់ស្រាវជ្រាវ**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ជំរុញ និងបង្កើតវប្បធម៌ប្រើប្រាស់ប្រព័ន្ធឌីជីថល។

**៣.២.១៥- ការបោះពុម្ព និងផ្សព្វផ្សាយ**

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ចងក្រង៖
    - ផែនការប្រចាំឆ្នាំ
    - សៀវភៅកត់ត្រា ដែលរំលេចព័ត៌មានសង្ខេបតាមមុខជំនាញ
    - ខិត្តប័ណ្ណ និងបដាព័ត៌មានសិក្សា
    - វីដេអូឃ្លីប អំពីសកម្មភាពនានារបស់ ស.អ.
    - សៀវភៅកម្មវិធីសិក្សា
    - សៀវភៅកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជា
    - របាយការណ៍ស្ទង់មតិនានា
    - និទ្ទេសបទស្វ័យវាយតម្លៃ សម្រាប់ គ.ទ.ក និង ឧស.
    - របាយការណ៍ស្តីពីការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ
    - គោលការណ៍ និងនីតិវិធីនានារបស់ ស.អ.
- បោះពុម្ព និងផ្សព្វផ្សាយ៖
    - សៀវភៅសិក្សាគោលនិងយោងតាមមុខជំនាញ
    - អាវយឺត ឡូហ្គោ នាមប័ណ្ណ និង កាតសម្គាល់ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង បុគ្គលិក គ្រូបង្រៀន/សាស្ត្រាចារ្យ និងនិស្សិត
    - ផែនការប្រចាំឆ្នាំ
    - សៀវភៅកត់ត្រា ដែលរំលេចព័ត៌មានសង្ខេបតាមមុខជំនាញ
    - ខិត្តប័ណ្ណ និងបដាព័ត៌មានសិក្សា
    - វីដេអូឃ្លីប អំពីសកម្មភាពនានារបស់ ស.អ.
    - សៀវភៅកម្មវិធីសិក្សា
    - របាយការណ៍ស្ទង់មតិនានា
    - និទ្ទេសបទស្វ័យវាយតម្លៃ សម្រាប់ គ.ទ.ក និង ឧស.
    - របាយការណ៍ស្តីពីការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ
    - គោលការណ៍ និងនីតិវិធីនានារបស់ ស.អ.

៣.២.១៦- ការពង្រឹង និងពង្រីកភាពជាដៃគូសហប្រតិបត្តិការ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បង្កើនដៃគូកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ
- ពង្រីកបណ្តាញទំនាក់ទំនងតាមប្រព័ន្ធបច្ចេកវិទ្យា។

៣.២.១៧- ការផ្លាស់ប្តូរវប្បធម៌

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បង្កើតឱកាសទស្សនកិច្ចសិក្សា ចូលរួមវេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានា នៅក្នុងប្រទេស និងបរទេស
- បង្កើតវេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានា នៅ ស.អ.។

៣.២.១៨- ការផ្តល់អាហារូបករណ៍

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- កំណត់ចំនួន និងប្រភេទអាហារូបករណ៍
- បង្កើតមូលនិធិសម្រាប់គាំទ្រដល់ការផ្តល់អាហារូបករណ៍។

៣.២.១៩- ការស្រាវជ្រាវរួមគ្នា

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បង្កើនគម្រោងស្រាវជ្រាវរួមគ្នា
- បង្កើតវប្បធម៌ស្រាវជ្រាវរួមគ្នា។

៣.២.២០- ការរៀបចំប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- បង្កើតស្តង់ដាធានាគុណភាពអប់រំផ្ទៃក្នុងរបស់ ស.អ.
- ជំរុញដំណើរការប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង។

៣.២.២១- ដំណើរការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- រៀបចំនិទ្ទេសបទស្វ័យវាយតម្លៃ
- បង្កើតវប្បធម៌ស្វ័យវាយតម្លៃ។

៣.២.២២- ការវាយតម្លៃគុណភាពអប់រំថ្នាក់ជាតិ/អន្តរជាតិ

ដើម្បីឆ្លើយតបទៅនឹងទិសដៅយុទ្ធសាស្ត្រខាងលើនេះ ស.អ. បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

- ចូលរួមអនុវត្តស្តង់ដារបស់ គ.ទ.ក អគ្គនាយកដ្ឋានឧត្តមសិក្សា និងនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីត្រៀមខ្លួនវាយតម្លៃ
- សិក្សាអំពីអត្ថប្រយោជន៍របស់ស្តង់ដា ISO។

# ជំពូក ៤
# លទ្ធផលរំពឹងទុក និងសកម្មភាពចម្បង

## ៤.១. ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិបាលកិច្ចច្បាស់លាស់

### ៤.១.១- ពិនិត្យការអនុវត្តការងារស្របតាមប្រព័ន្ធគ្រប់គ្រងរួម

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង ៖

- មានក្រុមប្រឹក្សាភិបាលយល់ដឹងច្បាស់លាស់អំពីប្រព័ន្ធគ្រប់គ្រងរួមរបស់ ស.អ.
- មានប្រព័ន្ធដឹកនាំ និងលំហូរការងារច្បាស់លាស់ ដើម្បីសម្រេចតាមចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល។

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- តម្រង់ទិសអំពីអភិបាលកិច្ច និងគោលការណ៍គ្រប់គ្រងរបស់ ស.អ.
- ស្ទង់មតិអំពីប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល
- បន្សុំប្រព័ន្ធការងារ ស.អ. ទៅនឹងចក្ខុវិស័យ បេសកកម្ម និងតម្លៃស្នូល។

## ៤.២. ការលើកកម្ពស់សមត្ថភាពបុគ្គលិក និងការលើកទឹកចិត្ត

### ៤.២.១-បង្កើនសមត្ថភាពបុគ្គលិករដ្ឋបាល

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានបុគ្គលិកចំនួន ១០០% ទទួលបានការអភិវឌ្ឍសមត្ថភាព។

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំផែនការអភិវឌ្ឍសមត្ថភាពបុគ្គលិក
- រៀបចំធ្វើបច្ចុប្បន្នភាពបុគ្គលិក។

### ៤.២.២- លើកទឹកចិត្តបុគ្គលិកគ្រប់កម្រិត

**ក. លទ្ធផលរំពឹងទុក**

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានបុគ្គលិកចំនួន ១០០% ទទួលបានការលើកទឹកចិត្តស្របតាមលទ្ធផលការងាររបស់ខ្លួន។

**ខ. សកម្មភាពការងារចម្បង**

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំផែនការលើកទឹកចិត្តបុគ្គលិក

- រៀបចំបញ្ជីឈ្មោះបុគ្គលិកដែលទទួលបានការលើកទឹកចិត្ត។

## ៤.៣. ការរៀបចំយន្តការដឹកនាំគ្រប់គ្រង និងប្រតិបត្តិការច្បាស់លាស់

### ៤.៣.១- កំណត់យន្តការដឹកនាំ និងគ្រប់គ្រង

#### ក. លទ្ធផលរំពឹងទុក

បន្ទាប់ពីអនុវត្តនូវទិសដៅខាងលើ សាកលវិទ្យាល័យនឹង៖

- មានយន្តការដឹកនាំ និងគ្រប់គ្រងច្បាស់លាស់។

#### ខ. សកម្មភាពការងារចម្បង

ដើម្បីសម្រេចបានដូចលទ្ធផលរំពឹងទុកខាងលើសកម្មភាពចម្បងមួយចំនួនត្រូវបានកំណត់ដូចតទៅ៖

- រៀបចំផែនការប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
